ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ:.០០២/០៨/កប/ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែមករា ឆ្នាំ២០០៧

# ប្រកាស

## ស្តីពី

## ការកំណត់ប្រភេទមុខរបរ និងការងារស្រាល ដែលអនុញ្ញាត ឱ្យកុមារអាចធ្វើការងារ ចាប់ពីអាយុ ១២ ដល់ ១៥ឆ្នាំ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងអនុក្រឹត្យ លេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## <u>សម្រេច</u>

**ប្រការ ១.-** និយោជកនៃសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ អាចអនុញ្ញាតឱ្យជួលប្រើប្រាស់ កុមារដែលមានអាយុ ១២ឆ្នាំ តែក្នុងប្រភេទការងារស្រាលៗ ដូចមានចែងក្នុងប្រការ[illegible] ។ កុមារដែលត្រូវធ្វើការជាផ្នែកមួយនៃការបណ្តុះបណ្តាលវិជ្ជាជីវៈក៏អាចធ្វើការ[illegible]ដូចមាន ចែងក្នុងប្រការ២ នៃប្រកាសនេះដែរ ។ ៥០៣

ប្រការ ២.- ការងារស្រាល គឺជាប្រភេទការងារទាំងនោះ មិនបណ្ដាលឱ្យខូចសុខភាព ឬការអភិវឌ្ឍន៍នៃចិត្ត និងកាយរបស់កុមារ និងមិនបណ្ដាលឱ្យប៉ះពាល់ដល់ការសិក្សាជាទៀងទាត់ ការចូលរួមក្នុងកម្មវិធីតម្រង់ទិស ឬការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដែលបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ។

ប្រភេទការងារស្រាលមានជាអាទិ៍:

១) ការងារកសិកម្មស្រាលៗខាងការងារចិញ្ចឹមសត្វ ការងារថែទាំប្រភេទសត្វស្រុកតូចៗ ប៉ុន្តែមិនមែនជាការចាប់និងសម្លាប់នូវប្រភេទសត្វទាំងនោះទេ ការងារដាំកូនឈើ ការងារប្រមូលកសិផល ការងារបេះផ្លែឈើ ប៉ុន្តែមិនមែនឡើងបេះទេ និងការងារបោសសំអាត ។

២) ការងារជម្រះស្មៅ និងឈូសឆាយដី

៣) ការងារកត់ត្រាទំនិញ

៤) ការងារនៅតាមហាងលក់ទំនិញមួយចំនួន ដូចជាស្តង់ តូបលក់បន្លែផ្លែឈើ ឬលក់សារព័ត៌មាន និងផលិតផល ប្រហាក់ប្រហែលជាដើម

៥) ការទទួល ការវេចខ្ចប់ ការជ្រើសរើស ការបែងចែកតាមប្រភេទទំនិញផ្សេងៗគ្នា និងការរៀបផ្ដុំរបស់ស្រាលៗ រួមទាំងពន្លា ឬដកទំនិញចេញពីកញ្ចប់

៦) ការបោសសំអាត ការជូតសំអាត និងការរៀបចំតុបាយ ដូចជាដាក់ចាន ស្លាបព្រា សម កាំបិត ជាដើម

៧) ការតំឡើងការងារហត្ថកម្មដែលមានលក្ខណៈងាយស្រួល ប៉ុន្តែមិនមែនជាការងារផ្សារលោហៈធាតុ ផ្សារដែក ឬការងារជាមួយផលិតផលដែលបង្កគ្រោះថ្នាក់នោះទេ

៨) ការងារលាបថ្នាំដោយមានប្រើឧបករណ៍ការពារ ប៉ុន្តែមិនមែនជាការងារបាញ់ថ្នាំពណ៌ទេ

៩) ការងារដែលមានលក្ខណៈងាយស្រួល ដូចជាផ្នែកដេរ ច្រកទំនិញចូលថង់ បត់ក្រដាស់ឡាំង ឬការដុស ខាត់ជូតកញ្ចក់ និងប្រដាប់ប្រដាធ្វើដោយសេរ៉ាមិច ឬការងារកាត់ព្រុយសំលៀកបំពាក់ ឬការចាប់ផ្ដុំ គ្រប់ផ្នែកផ្សេងៗនៃសម្លៀកបំពាក់ ឬជូតសំអាតភាពកខ្វក់ដែលប្រលាក់ជាប់លើផលិតផលសម្លៀកបំពាក់ ឬវៃផ្លាកយីហោ និងវៃផ្លាតម្លៃលក់ជាដើម ។

១០) រៀបចំ ឬរើសខោអាវតាមផ្នែកផ្សេងៗគ្នា សម្រាប់បោកសំអាត

១១) ការត្រួតពិនិត្យមើលផលិតផលនានា

១២) ការងារបញ្ជូនឯកសារផ្ទៃក្នុងអង្គភាព

១៣) ការយកសំបុត្រ ឬកញ្ចប់បញ្ញើស្រាលៗ ព្រមទាំងការចែកចាយសារព័ត៌មាន និងឯកសារផ្សេងៗ

១៤) ការរៀបចំទុកដាក់សៀវភៅនៅក្នុងបណ្ណាល័យ

១៥) លើកដាក់ឥវ៉ាន់ លី សែង យួរ កាន់របស់ស្រាលៗ NQHS

**ប្រការ ៣.-** នៅពេលជួលកុមារចាប់ពីអាយុ១២ ទៅ ១៥ឆ្នាំ និយោជកត្រូវឱ្យឪពុកម្ដាយ ឬអ្នកអាណាព្យាបាលរបស់កុមារនោះ យល់ដឹងអំពីលក្ខខណ្ឌការងារនៃការជួល រួមមានថិរវេលាធ្វើការងាររបស់កុមារ ពេលវេលាសម្រាប់ទៅសាលារៀន ភាពងាយរងគ្រោះថ្នាក់ និងជម្ងឺដែលបណ្ដាលមកពីការងារ វិធានការអនាម័យ និងសុវត្ថិភាពការងារដែលត្រូវបានអនុម័ត ។ និយោជកមានភារកិច្ចជម្រុញលើកទឹកចិត្តកុមារឱ្យទៅសាលារៀន ។

**ប្រការ ៤.-** ថិរវេលាធ្វើការងារប្រចាំថ្ងៃមិនត្រូវឱ្យលើសពី ៤ម៉ោង ចំពោះថ្ងៃសិក្សារៀនសូត្រ និងមិនលើសពី ៧ម៉ោង ចំពោះថ្ងៃសម្រាកពីការសិក្សា ។

ថិរវេលាធ្វើការងារជាក់ស្ដែងសរុបមិនត្រូវឱ្យលើសពី ១២ម៉ោង ក្នុងមួយសប្ដាហ៍សម្រាប់ថ្ងៃសិក្សា និងមិនឱ្យលើសពី ៣៥ម៉ោង ក្នុងមួយសប្ដាហ៍សម្រាប់សប្ដាហ៍ឈប់សម្រាកពីការសិក្សា ។

នៅទីកន្លែងដែលកុមារធ្វើការងារសម្រាប់និយោជកលើសពីមួយនាក់ ថិរវេលាធ្វើការងាររបស់កុមារ ត្រូវគណនាបញ្ចូលគ្នា ។ នៅទីកន្លែង ដែលថិរវេលាធ្វើការងារប្រចាំថ្ងៃរបស់កុមារលើសពី ៤ម៉ោង និង ៣០នាទី នោះកុមារ ធ្វើការងារត្រូវបានឈប់សម្រាកយ៉ាងហោចណាស់ ៣០នាទី ។ ការឈប់សម្រាកត្រូវរៀបចំឱ្យបានឈប់សម្រាកតែមួយដង ។

**ប្រការ ៥.-** កុមារដែលមានអាយុពី ១២ ទៅ ១៥ ឆ្នាំ មិនត្រូវធ្វើការពីម៉ោង ២០:០០ ដល់ ម៉ោង ០៦:០០ ព្រឹកទេ ។

**ប្រការ ៦.-** កុមារដែលមានអាយុពី ១២ ទៅ ១៥ឆ្នាំ ត្រូវទទួលបានរយៈពេលឈប់សម្រាកយ៉ាងហោចណាស់ ១៤ម៉ោង បន្តបន្ទាប់គ្នាក្នុងថិរវេលា ២៤ម៉ោង ។

**ប្រការ ៧.-** កុមារដែលមានអាយុពី ១២ ទៅ ១៥ឆ្នាំ ដែលធ្វើការងារស្រាលៗត្រូវទទួលបានថ្ងៃឈប់សម្រាកពីរថ្ងៃជាប់គ្នាក្នុងសប្ដាហ៍នីមួយៗ ។ ប៉ុន្តែ ជាធម្មតាមួយថ្ងៃគួរជាថ្ងៃអាទិត្យ ។

**ប្រការ ៨.-** ដូចមានចែងក្នុងប្រការ ៤ នៃប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា លេខ១០៦ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៤ ស្ដីពីការហាមឃាត់កុមារធ្វើការនៅកន្លែងការងារប្រកបដោយគ្រោះថ្នាក់ មន្ត្រីត្រួតពិនិត្យការងារនេះ ត្រូវឃ្លាំមើលជាប្រចាំនូវបញ្ជីប្រភេទការងារស្រាលដូចមានចែងក្នុងប្រការ២នៃប្រកាសនេះ ដើម្បីកំណត់អំពីការលើកលែងចាំបាច់ដែលសមស្រប ។ នៅក្នុងការប្រតិបត្តិនេះ មន្ត្រីត្រួតពិនិត្យត្រូវតែអនុវត្តតាមប្រការ៨ ដូចមានចែងក្នុងកថាខ័ណ្ឌខាងលើ ។

**ប្រការ ៩.-** អ្នកប្រព្រឹត្តិល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះត្រូវពិន័យឬទទួលទោសដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ ស្តីពីការងារ ។

**ប្រការ ១០.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

វង សុត

**<u>ចំលងជូន</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខអាន
- គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋានការងារ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង

"ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"

- សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា

"ដើម្បីអនុវត្ត"

- សហព័ន្ធសហជីព

"ដើម្បីជូនជ្រាប"

- គ្រប់បណ្តាញវិទ្យុនិងទូរទស្សន៍

"ដើម្បីជួយផ្សព្វផ្សាយ"

- កាលប្បវត្តិ និងឯកសារ